ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**តុលាការរដ្ឋប្បវេណី**
សំណុំរឿងលេខ : ១៧៥០
ចុះថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០១៩
សាលក្រមលេខ : ១២៨ " ខ "
ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០

# សាលក្រម
## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

-លោក [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

**ដើមចោទ :**

ឈ្មោះ [redacted] ចាន់ថា ភេទប្រុស អាយុ៥២ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅ [redacted] ។

**ចុងចម្លើយ :**

ចុងចម្លើយឈ្មោះ [redacted] ស៊ុនថានី ភេទស្រី អាយុ៥២ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅ [redacted] ។

**អ្នកតំណាងដោយអាណត្តិ :**

លោកស្រី [redacted] អត្តលេខ : [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានការិយាល័យស្ថិតនៅ [redacted] ។

លោក [redacted] អត្តលេខ : [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានការិយាល័យស្ថិតនៅ [redacted] ។

## អង្គហេតុ និងចំណុចវិវាទ

**ក-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ**

១-សុំលែងលះពីប្រពន្ធឈ្មោះ [redacted] ស៊ុនថានី ។

២-ទ្រព្យសម្បត្តិរួម : [redacted] មានលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ : ១៧២៨/០៥ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៥ ចេញដោយអភិបាលខណ្ឌទួលគោក ខ្លួនស្នើសុំឲ្យតុលាការបែងចែកទុកឲ្យកូនទាំងពីរនាក់ ។

Scanned with CamScanner

៣-បំណុលរួម គ្មាន ។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

## ខ-ដំណើររឿងក្ដី និង ចំណុចវិវាទ

### ខ.១-ការសង្ខេបអំពីរឿងក្ដី

ដើមចោទឈ្មោះ [redacted] ចាន់ថា និង ចុងចម្លើយឈ្មោះ [redacted] ស៊ុនថានី បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាមប្រពៃណី កាលពីអំឡុងឆ្នាំ១៩៩២ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ផ្សារដេប៉ូទី២ មានសំបុត្រអាពាហ៍ពិពាហ៍លេខ ០២ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៦ ។ ក្នុងការរស់នៅជាមួយគ្នាកន្លងមកមានកូន២នាក់ គឺកូនទី១: ឈ្មោះ [redacted] ស្រីនាង ភេទស្រី កើតនៅថ្ងៃទី [redacted] និងកូនទី២ : ឈ្មោះ [redacted] ស្រីនិត ភេទស្រី កើតនៅថ្ងៃទី [redacted] មានវ័យនីតិភាពរស់ហើយ ។

ក្នុងអំឡុងរស់នៅជាមួយគ្នាមានទ្រព្យសម្បត្តិរួម : [redacted] មានលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ : ១៧២៨/០៥ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៥ ចេញដោយអភិបាលខណ្ឌទួលគោក ។

មូលហេតុប្ដឹងសុំលែងលះ ដោយសារការរស់នៅមិនចុះសម្រុងនឹងគ្នា មានបញ្ហាមិនចេះចប់មិនចេះហើយ មានភាពរកាំរកូស ខ្វែងគំនិតគ្នា និងទាស់សម្ដីគ្នាជាញឹកញាប់ ជាហេតុធ្វើឱ្យគូភាគីអស់មនោសញ្ចេតនាក្នុងការរួមរស់ជាប្ដីប្រពន្ធជាមួយគ្នាតទៅទៀតបានទេ ។

### ខ.២-អង្គហេតុដែលអះអាងដោយដើមចោទ

ដើមចោទឈ្មោះ [redacted] ចាន់ថា បានថ្លែងការណ៍ថា : ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted] ស៊ុនថានី តាមប្រពៃណីកាលពីអំឡុងឆ្នាំ១៩៩២ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ផ្សារដេប៉ូ២ ដូចមានសំបុត្រអាពាហ៍ពិពាហ៍លេខ ០២ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៦ ។ ក្នុងការរស់នៅជាមួយគ្នាមានកូន០២នាក់ គឺកូនទី១ : ឈ្មោះ [redacted] ស្រីនាង ភេទស្រី កើតនៅថ្ងៃទី [redacted] និងកូនទី២ : ឈ្មោះ [redacted] ស្រីនិត ភេទស្រី កើតនៅថ្ងៃទី [redacted] ប៉ុន្តែកូនពីរនាក់នេះមានវ័យនីតិភាពរស់ហើយ ។

ក្នុងអំឡុងរស់នៅជាមួយគ្នាមានទ្រព្យសម្បត្តិរួម : [redacted] មានលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ : ១៧២៨/០៥ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៥ ចេញដោយអភិបាលខណ្ឌទួលគោក ហើយទ្រព្យសម្បត្តិរួមខាងលើនេះ ខ្លួនសុំឱ្យតុលាការបែងចែកទុកឱ្យកូនទាំងពីរនាក់ ។

មូលហេតុដែលខ្លួនសុំលែងលះពីចុងចម្លើយឈ្មោះ [redacted] ស៊ុនថានី ដោយសារការរស់នៅមិនចុះសម្រុងនឹងគ្នា មានបញ្ហាមិនចេះចប់មិនចេះហើយ មានភាពរកាំរកូស ខ្វែងគំនិតគ្នា និងទាស់សម្ដីគ្នាជាញឹកញាប់ម្យ៉ាងទៀត ខ្លួន និងចុងចម្លើយបានបែកលំនៅសង្វាសពីគ្នាអស់រយៈពេល ៧ខែ ទៅ ៨ខែមកហើយ ដែលជាហេតុធ្វើឱ្យខ្លួនអស់មនោសញ្ចេតនាក្នុងការរួមរស់ជាប្ដីប្រពន្ធជាមួយគ្នាតទៅទៀត ។ ដូច្នេះទើបខ្លួនស្នើសុំឱ្យតុលាការសម្រេចសេចក្ដីលែងលះ និងបែងចែកទ្រព្យសម្បត្តិរួមខាងលើនេះទុកឱ្យកូនទាំងពីរនាក់ ។



Scanned with CamScanner

### ខ.៣-អង្គហេតុដែលអះអាងដោយចុងចម្លើយ

ចុងចម្លើយឈ្មោះ [redacted] ស៊ីនថានី បានថ្លែងការណ៍តបថា : ខ្លួនពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយដើមចោទឈ្មោះ [redacted] ចាន់ថា តាមប្រពៃណី កាលពីអំឡុងឆ្នាំ១៩៩២ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ផ្សារដេប៉ូ២ ដូចមានសំបុត្រអាពាហ៍ពិពាហ៍លេខ ០២ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៦ ប្រាកដមែន ។ ក្នុងការរស់នៅជាមួយគ្នាមានកូន០២នាក់ គឺកូនទី១ : ឈ្មោះ [redacted] ស្រីនាង ភេទស្រី កើតនៅថ្ងៃទី [redacted] និងកូនទី២ : ឈ្មោះ [redacted] ស្រីនិត ភេទស្រី កើតនៅថ្ងៃទី [redacted] ប៉ុន្តែពួកគាត់ទាំងពីរនាក់មានវ័យនីតិភាពអស់ហើយ ។

ក្នុងអំឡុងរស់នៅជាមួយគ្នាមានទ្រព្យសម្បត្តិរួម : [redacted] មានលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ : ១៧២៨/០៥ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៥ ចេញដោយអភិបាលខណ្ឌទួលគោក ខ្លួនឯកភាពប្រគល់ទៅឱ្យកូនពីរនាក់ ឈ្មោះ [redacted] ស្រីនាង ភេទស្រី និងឈ្មោះ [redacted] ស្រីនិត ភេទស្រី តាមការប្តឹងសុំរបស់ដើមចោទ ។

មូលហេតុដែលឈានដល់ការលែងលះគ្នា គឺដោយសារការរស់នៅមិនចុះសម្រុងនឹងគ្នា មានបញ្ហាមិនចេះចប់មិនចេះហើយ មានភាពរកាំរកូស ខ្វែងគំនិតគ្នា និងទាស់សម្តីគ្នាជាញឹកញាប់ ម្យ៉ាងទៀត ខ្លួន និងដើមចោទបានបែកលំនៅសង្វាសពីគ្នាអស់រយៈពេល៧ខែ ទៅ ៨ខែមកហើយ ដែលជាហេតុធ្វើឱ្យខ្លួនអស់មនោសញ្ចេតនាក្នុងការរួមរស់ជាប្តីប្រពន្ធជាមួយគ្នាតទៅទៀត ដោយបានព្រមព្រៀងគ្នាលែងលះ និងបែងចែកទ្រព្យសម្បត្តិរួមទុកឱ្យកូនទាំងពីរនាក់ ។

### ខ.៤-ការអះអាងដោយភាគីកូន

កូនឈ្មោះ [redacted] ស្រីនាង បានថ្លែងការណ៍ថា : ខ្លួនសុខចិត្តទទួលយកនូវអចលនវត្ថុ ផ្ទះលេខ ២១ $AE_0E_1$ ផ្លូវលេខ៥៧៦ ក្រុម១០ ភូមិ២ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ : ១៧២៨/០៥ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៥ ចេញដោយអភិបាលខណ្ឌទួលគោក ដែលឪពុករបស់ខ្លួនឈ្មោះ [redacted] ចាន់ថា និងម្តាយឈ្មោះ [redacted] ស៊ីនថានី បានព្រមព្រៀងគ្នាប្រគល់អចលនវត្ថុផ្ទះខាងលើនេះមកឱ្យខ្លួន និងប្អូនឈ្មោះ [redacted] ស្រីនិត មានសិទ្ធិគ្រប់គ្រងតាមច្បាប់តទៅ ។

កូនឈ្មោះ [redacted] ស្រីនិត បានថ្លែងការណ៍ថា : ខ្លួនសុខចិត្តទទួលយកនូវអចលនវត្ថុ ផ្ទះលេខ ២១ $AE_0E_1$ ផ្លូវលេខ៥៧៦ ក្រុម១០ ភូមិ២ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ : ១៧២៨/០៥ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៥ ចេញដោយអភិបាលខណ្ឌទួលគោក ដែលឪពុករបស់ខ្លួនឈ្មោះ [redacted] ចាន់ថា និងម្តាយឈ្មោះ [redacted] ស៊ីនថានី បានព្រមព្រៀងគ្នាប្រគល់អចលនវត្ថុផ្ទះខាងលើនេះមកឱ្យខ្លួន និងបងឈ្មោះ [redacted] ស្រីនាង មានសិទ្ធិគ្រប់គ្រងតាមច្បាប់តទៅ ។

### គ-អង្គហេតុដែលគ្មានវិវាទ :

-គូភាគីទទួលស្គាល់ថា បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់ ។



Scanned with CamScanner

-គូភាគីឯកភាពគ្នា លើការលែងលះ ។

-គូភាគីឯកភាពគ្នា កូនពីរនាក់ គឺឈ្មោះ [redacted] ស្រីនាង ភេទស្រី កើតនៅថ្ងៃទី[redacted] និងឈ្មោះ [redacted] ស្រីនិត ភេទស្រី កើតនៅថ្ងៃទី[redacted]តែកូនមានវ័យនីតិភាពអស់ហើយ ។

-គូភាគីឯកភាពគ្នាថា មានទ្រព្យសម្បត្តិរួម គឺ : ផ្ទះលេខ៦១ AE0E1 ផ្លូវលេខ៥៧៦ ក្រុម១០ ភូមិ២ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ : ១៧២៨/០៥ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៥ ចេញដោយអភិបាលខណ្ឌទួលគោក ហើយទ្រព្យសម្បត្តិរួមខាងលើនេះ គូភាគីសុខចិត្តប្រគល់ទុកឱ្យកូនពីរនាក់ ឈ្មោះ [redacted]ស្រីនាង ភេទស្រី កើតនៅឆ្នាំ១៩៩២ និងឈ្មោះ [redacted] ស្រីនិត ភេទស្រី កើតនៅឆ្នាំ១៩៩៤ ។

**ឃ-ចំណុចវិវាទ** : គ្មាន ។

**ការពិនិត្យភស្តុតាង**

**១.ភស្តុតាងជាឯកសាររបស់ដើមចោទឈ្មោះ [redacted] ចាន់ថា**

១.១-សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍លេខ : ០២ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៦ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ផ្សារដេប៉ូទី២ ។

១.២-សៀវភៅគ្រួសារ ។

១.៣-សៀវភៅស្នាក់នៅចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ចេញដោយអធិការនគរបាលខណ្ឌទួលគោក ។

១.៤-លិខិតផ្ទេរសិទ្ធិកាន់កាប់លេខ : ១៧២៨/០៥ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៥ ចេញដោយលោកអភិបាលខណ្ឌទួលគោក ។

**២.ភស្តុតាងជាឯកសាររបស់ចុងចម្លើយឈ្មោះ [redacted] ស៊ុនថានី**

២.១-កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ របស់ធនាគារ[redacted]សាខាពោធិ៍ចិនតុង ។

**<u>សំអាងហេតុ</u>**

ផ្អែកតាមលទ្ធផលនៃការសាកសួរសាមីភាគី និងការពិនិត្យភស្តុតាង ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការយល់ឃើញថា :

**១-ដើមចោទឈ្មោះ [redacted] ចាន់ថា** និងចុងចម្លើយឈ្មោះ [redacted] **ស៊ុនថានី** ពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាមប្រពៃណី កាលពីអំឡុងឆ្នាំ១៩៩២ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ផ្សារដេប៉ូទី២ លេខ : ០២ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៦ ដូច្នេះ ដើមចោទឈ្មោះ [redacted] **ចាន់ថា** និងចុងចម្លើយឈ្មោះ [redacted] **ស៊ុនថានី** ពិតជាប្តីប្រពន្ធស្របច្បាប់ ។

**២-ដើមចោទឈ្មោះ [redacted] ចាន់ថា** និង ចុងចម្លើយឈ្មោះ [redacted] **ស៊ុនថានី** បានព្រមព្រៀងលែងលះគ្នាដោយស្ម័គ្រចិត្តរៀងៗខ្លួន ដោយហេតុថា ការរស់នៅមិនចុះសម្រុងនឹងគ្នា និងបានបែកលំនៅសម្ងាសពីគ្នាក្នុងរយៈពេល០៧ខែ ទៅ ០៨ខែមកហើយ ជាហេតុបណ្តាលឱ្យគូភាគីអស់មនោសញ្ចេតនាជាប្តីប្រពន្ធ ទោះបីជាតុលាការខំព្យាយាមផ្សះផ្សាគ្រប់ដំណាក់កាលក៏ដោយ ក៏គូភាគីមិនព្រមសះជានឹងគ្នាវិញដែរ សបញ្ជាក់ឱ្យឃើញថា ភាគីទាំងសងខាងមានបំណងពិតប្រាកដក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ ហើយគោលដៅនៃអាពាហ៍



Scanned with CamScanner

ពិពាហ៍លែងបានសម្រេច គប្បីតុលាការធ្វើការសម្រេចអំពីបញ្ហានេះ តាមការព្រមព្រៀងរបស់គូភាគីតាមបញ្ញត្តិ មាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី ។

៣-ក្នុងអំឡុងពេលរស់នៅជាមួយគ្នាមានកូន០២នាក់គឺ :

៣.១-ឈ្មោះ [redacted] ស្រីនាង ភេទស្រី កើតនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩២ ។

៣.២-ឈ្មោះ [redacted] ស្រីនិត ភេទស្រី កើតនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ។

ឃើញថា កូនឈ្មោះ [redacted] ស្រីនាង ភេទស្រី និងឈ្មោះ [redacted] ស្រីនិត ភេទស្រី មាននីតិភាពហើយ គប្បីតុលាការមិនសម្រេចអំពីអ្នកមានសិទ្ធិអំណាចមេបានោះទេ ។

៤-នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២ គូភាគីបានឯកភាពគ្នាក្នុងការបែងចែកទ្រព្យសម្បត្តិរួម : ផ្ទះលេខ២១ AE0E1 ផ្លូវលេខ៥៧៦ ក្រុម១០ ភូមិ២ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ : ១៧២៨/០៥ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៥ ចេញដោយអភិបាលខណ្ឌទួលគោក ទុកឲ្យកូនពីរនាក់ឈ្មោះ [redacted] ស្រីនាង ភេទស្រី និងឈ្មោះ [redacted] ស្រីនិត ភេទស្រី ។ រីឯកូនឈ្មោះ [redacted] ស្រីនាង ភេទស្រី និងឈ្មោះ [redacted] ស្រីនិត ភេទស្រី នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ពួកគេក៏សុខចិត្តទទួលយកទ្រព្យដែលឪពុកម្តាយប្រគល់មកឲ្យពួកគេ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី តាមបញ្ញត្តិមាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី ។

៥-ចុងចម្លើយឈ្មោះ [redacted] ស៊ុនថានី គឺជាស្ត្រី គប្បីតុលាការសម្រេចឲ្យស្ថិតក្នុងភាពមេម៉ាយ ដើម្បីហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីក្នុងអំឡុងពេល១២០ថ្ងៃ គិតពីថ្ងៃសម្រេចអំពីការលែងលះតាមបញ្ញត្តិមាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណី ។

៦-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ និងចុងចម្លើយក្នុងចំណែកស្មើៗគ្នា ។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១-ឈ្មោះ [redacted] ចាន់ថា លែងលះពីឈ្មោះ [redacted] ស៊ុនថានី ។

២-ទ្រព្យសម្បត្តិរួម មាន : ផ្ទះលេខ២១ AE0E1 ផ្លូវលេខ៥៧៦ ក្រុម១០ ភូមិ២ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ : ១៧២៨/០៥ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៥ ចេញដោយអភិបាលខណ្ឌទួលគោក ។

ប្រគល់ឲ្យទៅកូនពីរនាក់ ឈ្មោះ [redacted] ស្រីនាង ភេទស្រី កើតនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩២ និងឈ្មោះ [redacted] ស្រីនិត ភេទស្រី កើតនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩៤ គ្រប់គ្រងជាម្ចាស់សហកម្មសិទ្ធិ ។

៣-ឲ្យឈ្មោះ [redacted] ស៊ុនថានី ស្ថិតក្នុងភាពមេម៉ាយក្នុងរយៈពេល ១២០ថ្ងៃ គិតពីថ្ងៃប្រកាសសាលក្រម ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ និងចុងចម្លើយក្នុងចំណែកស្មើគ្នា ។



Scanned with CamScanner

សាលក្រមនេះ ត្រូវបានប្រកាសនៅសវនាការជាអសាធារណៈ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ។ ក្នុងករណីដែលប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល ០១(មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ ។

**ចៅក្រម**

ហត្ថលេខា និងត្រា : [redacted]

......................................................................................................................................................

" បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម "

ថ្ងៃចន្ទ ២រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ,ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]